# មុខកថា

ផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំ ជាចំណុចគន្លឹះសម្រាប់ឈានទៅសម្រេចជោគជ័យក្នុងការប្រែក្លាយវិទ្យាស្ថានជាតិអប់រំ ឲ្យទៅជាគ្រឹះស្ថានឧត្តមសិក្សាមួយដែលមានការទទួលស្គាល់កម្រិតតំបន់ និងចាត់ទុកថាជាគ្រឹះស្ថានបណ្តុះបណ្តាលអ្នកស្រាវជ្រាវអប់រំ គ្រូបង្រៀនកម្រិតឧត្តម អ្នកដឹកនាំ និងអ្នកគ្រប់គ្រងវិស័យអប់រំ ។

ក្រសួងអប់រំ យុវជន និងកីឡា មានគោលដៅធ្វើឲ្យសម្រេចបានសមធម៌នៃការចូលរៀន និងកំពុងយកចិត្តទុកដាក់ក្នុងការពង្រឹងគុណភាពអប់រំតាមរយៈការពង្រឹងស្ថាប័ន និងសមត្ថភាពរបស់គ្រូឧទ្ទេស និងមន្ត្រីគ្រប់គ្រង។

ផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំ គឺជាផែនការមួយដែលមានលក្ខណៈប្រតិបត្តិក្នុងការបណ្តុះបណ្តាលគ្រូប្រកបដោយគុណភាព។ គ្រូជាគន្លឹះដ៏សំខាន់សម្រាប់រួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្សឲ្យមានការគិតកម្រិតខ្ពស់មានភាពម្ចាស់ការក្នុងការរៀនសូត្រក៏ដូចជាកាត់បន្ថយកត្តាត្រួតថ្នាក់និងការបោះបង់ការសិក្សារបស់សិស្ស។ ផែនការនេះបានកំណត់នូវចំណុចខ្លាំង និងចំណុចខ្សោយដែលវិទ្យាស្ថានជាតិអប់រំកំពុងជួបប្រទះព្រមទាំងបានដាក់ស្នើឡើងនូវយុទ្ធសាស្ត្រសម្រាប់អនុវត្ត។ គណៈនាយក មន្ត្រីគ្រប់គ្រងបុគ្គលិកសាស្ត្រាចារ្យត្រូវតែមានគោលដៅច្បាស់លាស់ហើយខិតខំចូលរួមយ៉ាងសកម្ម ដើម្បីសម្រេចឲ្យបាននូវលទ្ធផលជាក់លាក់ និងស្របទៅតាមទិសដៅដែលបានកំណត់។

ក្រសួងអប់រំ យុវជន និងកីឡា មានក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការនេះ នឹងត្រូវយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយមានការផ្គត់ផ្គង់ទាំងសម្ភារ ថវិកា និងបច្ចេកទេសពីអង្គភាព និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ហើយរាល់ការរីកចម្រើន នឹងត្រូវបានពិនិត្យតាមដាន និងវាយតម្លៃតាមកម្រិតស្តង់ដារមួយជាក់លាក់។

ក្រសួង សូមថ្លែងអំណរគុណដោយស្មោះចំពោះមន្ត្រីជំនាញជាតិ និងអន្តរជាតិដែលបានបំពេញការងារយ៉ាងល្អិតល្អន់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែវិច្ឆិកា ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

# សេចក្តីផ្តើម

ផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំ បានរៀបចំឡើងដោយគណៈកម្មការផែនការ និងគ្រប់គ្រងអប់រំ និងមានការជួយគាំទ្រពីសំណាក់គណៈកម្មការសម្របសម្រួល និងគណៈគ្រប់គ្រងវិទ្យាស្ថានជាតិអប់រំ។ ផែនការនេះចាប់ផ្តើមតាក់តែងឡើងនាខែកក្កដា ឆ្នាំ២០០៩ ហើយបានបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០១០។ ដើម្បីរៀបចំផែនការដ៏មានសារៈសំខាន់នេះគណៈកម្មការបានចំណាយពេលវេលាយ៉ាងច្រើនដើម្បីវិភាគពីស្ថានភាពបច្ចុប្បន្នរបស់វិទ្យាស្ថានជាតិអប់រំ ដោយពិចារណាបង្កើតចក្ខុវិស័យសម្រាប់វិទ្យាស្ថាន ព្រមទាំងបានបន្សុំឲ្យមានលក្ខណៈសមស្របទៅនឹងគោលដៅនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ បន្ទាប់មកគណៈកម្មការបានអភិវឌ្ឍឡើងនូវយុទ្ធសាស្រ្តជាគន្លឹះចំនួន២៩ សម្រាប់អនុវត្តដើម្បីធ្វើឲ្យវិទ្យាស្ថានជាតិអប់រំមានការរីកចម្រើននាពេលអនាគត។

ដំណើរការអភិវឌ្ឍន៍ផែនការនេះ បានប្រព្រឹត្តទៅដោយឈរលើគោលការណ៍ចូលរួម និងកិច្ចពិគ្រោះយោបល់។ រាល់ចំណុចនីមួយៗដែលបានសម្រេចឡើង សុទ្ធតែត្រូវបានចំណាយពេលវេលាពិគ្រោះយោបល់ជាមួយមន្រ្តី សាស្រ្តាចារ្យ គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ និងភាគីពាក់ព័ន្ធនានា។ រាល់គំនិត ទស្សនៈ និងយោបល់ដែលបានលើកឡើងត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងផែនការចុងក្រោយ តាមរយៈការប្រជុំក្រុមបច្ចេកទេស និងការធ្វើសិក្ខាសាលាពិគ្រោះយោបល់ជាច្រើន។ គោលការណ៍ជាមូលដ្ឋានសំខាន់ៗ នៃការរៀប ចំផែនការនេះ បានបង្ហាញនូវភាពម្ចាស់ការ ធានាបាននូវការវិវត្តឈានឡើងរបស់មន្រ្តីគ្រប់គ្រង និងសាស្រ្តាចារ្យដែលអាចនឹងកើតមានឡើងនាពេលខាងមុខក្នុងការអនុវត្តផែនការនេះជាក់ជាមិនខាន។

ឯកសារផែនការនេះ បានបរិយាយជាសង្ខេបនូវស្ថានភាពបច្ចុប្បន្ន និងការរំពឹងទុកថាវិទ្យាស្ថានជាតិអប់រំនឹងមានការរីកចម្រើនដូចវិទ្យាស្ថានអប់រំនានាក្នុងតំបន់នាពេលអនាគត។

ផែនការអភិវឌ្ឍន៍នេះបានរៀបរាប់ចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្រ្ត ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ដែលទាមទារឲ្យមានការប្តេជ្ញាចិត្ត និងការព្យាយាមយ៉ាងមុះមុតផងដែរ។ ផែនការនេះតម្រូវឲ្យមានការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ សម្រាប់តម្រង់ទិសសកម្មភាព ព្រមទាំងជាឧបករណ៍វាយតម្លៃ និងធ្វើរបាយការណ៍រីកចម្រើននានាជូនដល់ភាគីដែលពាក់ព័ន្ធ។

គណៈគ្រប់គ្រង មន្រ្តី និងសាស្រ្តាចារ្យនៃវិទ្យាស្ថានជាតិអប់រំ សង្ឃឹមថាភាគីពាក់ព័ន្ធនានានឹងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំនេះ។ វិទ្យាស្ថានជាតិអប់រំសង្ឃឹមយ៉ាងមុតមាំថានឹងទទួលបានការគាំទ្រតាមគ្រប់មធ្យោបាយ ពីសំណាក់ភាគីពាក់ព័ន្ធនានាសំដៅធ្វើយ៉ាងណាឲ្យវិទ្យាស្ថានជាតិអប់រំ "ត្រូវបានទទួលស្គាល់ថាជាស្ថាប័នឈានមុខគេ លើការបណ្តុះបណ្តាលអ្នកស្រាវជ្រាវអប់រំ គ្រូបង្រៀនកម្រិតឧត្តម មន្រ្តីផែនការ អ្នកដឹកនាំ និងអ្នកគ្រប់គ្រងក្នុងវិស័យអប់រំ "។

ផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំនេះបានឆ្លងកាត់ការសិក្សាស្រាវជ្រាវត្រួតពិនិត្យ និងវាយតម្លៃដ៏ពេញលេញ អំពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងឧបសគ្គនានា ដែលកំពុងជួបប្រទះសព្វថ្ងៃ។

លទ្ធផលស្រាវជ្រាវបានរកឃើញថា វប្បធម៌ការងាររបៀបចាត់ចែង និងរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិអប់រំ ចាំបាច់ត្រូវធ្វើការកែសម្រួលឲ្យប្រសើរឡើង ដើម្បីធ្វើឲ្យវិទ្យាស្ថាននេះ ក្លាយជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខគេ ព្រមទាំងមានស្តង់ដារខ្ពស់លើការងារស្រាវជ្រាវអប់រំ ការបណ្តុះបណ្តាលគ្រូ អ្នកដឹកនាំ និងអ្នកគ្រប់គ្រងវិស័យអប់រំ។

# ជំពូកទី១

## ការវិភាគស្ថានភាពបច្ចុប្បន្ន

វិទ្យាស្ថានជាតិអប់រំមានបទពិសោធច្បាស់លាស់ពាក់ព័ន្ធនឹងវិស័យបណ្តុះបណ្តាលនៅកម្ពុជា ព្រមទាំងមានទីតាំងស្ថិតត្រង់បេះដូងនៃរាជធានីភ្នំពេញ ដែលអ្នកផងឲ្យតម្លៃហើយមានភាពងាយស្រួលចេញចូលសម្រាប់និស្សិត និងមន្ត្រីរាជការទាំងឡាយដែលមានបំណងចង់បំប៉នចំណេះដឹងផ្នែកចិត្តគរុកោសល្យ ភាពជាអ្នកដឹកនាំការធ្វើផែនការ និងការគ្រប់គ្រងវិស័យអប់រំ។ គរុនិស្សិតដែលសិក្សានៅទីនេះមានការប្តេជ្ញាចិត្ត និងព្យាយាមដោយមានកម្មវិធីបណ្តុះបណ្តាលល្អ ព្រមទាំងសាស្ត្រាចារ្យមានបទពិសោធខ្ពស់។ ក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាមន្ត្រីអប់រំ ព្រមទាំងមាតាបិតាសិស្សមានបំណងចង់ឃើញវិទ្យាស្ថានជាតិអប់រំរីកចម្រើន និងក្លាយទៅជាស្ថាប័នឧត្តមសិក្សាមួយដែលផ្តល់គុណភាពអប់រំទៅដល់សិស្ស និស្សិត និងសិក្ខាកាមយ៉ាងវិសេសវិសាលលើសគេនៅក្នុងប្រទេសក៏ដូចជានៅក្នុងតំបន់។

ទោះជាយ៉ាងណាក៏ដោយក៏វិទ្យាស្ថានជាតិអប់រំ នៅមានអាគារសិក្សាជាច្រើនមិនទាន់បានបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់និងមួយចំនួនធំត្រូវការជួសជុលនិងកែលម្អ សព្វថ្ងៃការប្តេជ្ញាចិត្តចូលរួមចំណែកក្នុងការអភិវឌ្ឍស្ថាប័នរបស់មន្ត្រីវិទ្យាស្ថាននៅមានកម្រិតហើយសកម្មភាពបង្រៀន និងរៀននៅមានលក្ខណៈគ្រូមជ្ឈមណ្ឌលច្រើនជាងសិស្សមជ្ឈមណ្ឌល។

រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានបង្ហាញឆន្ទៈ និងបំណងប្រាថ្នាចង់ឃើញវិទ្យាស្ថានជាតិអប់រំមានលក្ខណៈឈានមុខគេនៅកម្ពុជា។ ទស្សនៈវិស័យនេះមានបញ្ជាក់នៅក្នុងអនុក្រឹត្យលេខ០៤ ចុះថ្ងៃទី១១ ខែមិនាឆ្នាំ២០០៩ និងអនុក្រិត្យលេខ៨៤ ចុះថ្ងៃទី៩ ខែមិថុនាឆ្នាំ២០០៩។ ដៃគូអភិវឌ្ឍនិងអង្គការនានាប្រាថ្នាចង់ផ្តល់ការគាំទ្រដល់កិច្ចការងាររបស់វិទ្យាស្ថានជាតិអប់រំឲ្យមានការរីកចម្រើនចំណែកឯនិស្សិត និងមន្ត្រីវិទ្យាស្ថានជាតិអប់រំចង់ឲ្យមានការដាក់បញ្ចូលបច្ចេកវិទ្យាទំនើបក្នុងការបង្រៀន និងរៀន។ សព្វថ្ងៃនេះថវិកាគាំទ្រដល់វិទ្យាស្ថានជាតិអប់រំនៅមានកម្រិត។

វិទ្យាស្ថានជាតិអប់រំមានចក្ខុវិស័យ និងបេសកកម្មច្បាស់លាស់។ ទស្សនៈវិស័យនេះ គឺឆ្លើយតបទៅនឹងតម្រូវការនិងទស្សនៈចង់បានពីសំណាក់អ្នកទទួលសេវាអប់រំ ហើយវាជាតម្រូវការចាំបាច់របស់ក្រសួងអប់រំយុវជននិងកីឡាតាមរយៈការស្រាវជ្រាវនានាដើម្បីជំរុញលើកកម្ពស់វិស័យអប់រំនៅកម្ពុជា។ វិទ្យាស្ថានជាតិអប់រំ នឹងមានសមត្ថភាពវិភាគទិន្នន័យនានារបស់ក្រសួងបានយ៉ាងពេញលេញ ដើម្បីផ្តល់អនុសាសន៍ អំពីយុទ្ធសាស្ត្រនានាដែលអាចអនុវត្តបាន។

ជាមួយគ្នានឹងសេចក្តីបញ្ជាក់ជុំវិញស្ថានភាពបច្ចុប្បន្នចក្ខុវិស័យនិងបេសកកម្មផែនការនេះបានកំណត់ចំណុចគន្លឹះសម្រាប់អភិវឌ្ឍចំនួន៨ ស្របគ្នានឹងការរំពឹងទុកដែលនឹងត្រូវអនុវត្តដោយវិទ្យាស្ថានជាតិអប់រំ ចំណុចគន្លឹះនីមួយៗ មានសង្ខេបអំពីបរិបទ និងយុទ្ធសាស្ត្រដែលនឹងត្រូវយកទៅអនុវត្តសម្រាប់រយៈពេល៥ឆ្នាំចំណុចជាគន្លឹះទាំង៨នោះរួមមាន៖ ការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍបុគ្គលិក ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល ការវាយតម្លៃ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការធានាគុណភាពការស្រាវជ្រាវ និងការបង្កើតទំនាក់ទំនង សាធារណៈ។ ផែនការអភិវឌ្ឍន៍វិទ្យាស្ថានជាតិអប់រំនេះមានលក្ខណៈសង្ខេប និងផ្តល់ទិសដៅជាក់លាក់សម្រាប់ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំដែលជាមាគ៌ាក្នុងការអនុវត្ត។

# ជំពូកទី២

# ចក្ខុវិស័យ

## I- ចក្ខុវិស័យ

វិទ្យាស្ថានជាតិអប់រំ ជាស្ថាប័នឈានមុខគេក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម អ្នកដឹកនាំស្ថាប័នអប់រំ មន្រ្តីគ្រប់គ្រងអប់រំ និងអ្នកវាយតម្លៃគុណភាពអប់រំ។

## II- បេសកកម្ម

ផ្តល់ជូនប្រកបដោយគុណភាពខ្ពស់នូវ៖

- អ្នកស្រាវជ្រាវ និងអ្នកវាយតម្លៃ
- ការបណ្តុះបណ្តាលគ្រូដែលអនុវត្តគរុកោសល្យទំនើប
- អ្នកដឹកនាំ អ្នកគ្រប់គ្រង នាយកសាលា គ្រូបង្រៀន ដែលមានស្តង់ដាខ្ពស់។

## III- គុណតម្លៃ

វិទ្យាស្ថានជាតិអប់រំប្តេជ្ញាអនុវត្តដោយឈរលើគោលការណ៍៖

- សហប្រតិបត្តិការ
- គុណភាព
- គំនិតច្នៃប្រឌិត
- ការបង្កើតថ្មី
- តម្លាភាព
- វប្បធម៌សន្តិភាព
- ការទទួលខុសត្រូវ
- ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយចិរភាព។

# ជំពូកទី៣

# យុទ្ធសាស្រ្ត

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មខាងលើ វិទ្យាស្ថានជាតិអប់រំបានរៀបចំយុទ្ធសាស្រ្តដូចតទៅ៖

## I- ការអភិវឌ្ឍស្ថាប័ន

១. រៀបចំឡើងវិញនូវសមត្ថភាពរបស់ស្ថាប័ន ដោយបង្កើតរចនាសម្ព័ន្ធថ្មី។

២. ពិនិត្យគោលនយោបាយបំពេញការងារបច្ចុប្បន្នរបស់បុគ្គលិក ដើម្បីបង្កើតគោលនយោបាយថ្មី។

៣. បង្កើតកម្មវិធីផ្លាស់ប្តូរទម្លាប់មួយ។

៤. បង្កើតសៀវភៅមគ្គុទ្ទេសក៍ដឹកនាំ និងការគ្រប់គ្រង។

៥. បង្កើតឲ្យមានក្រុមប្រឹក្សាភិបាល។

## II- ការអភិវឌ្ឍបុគ្គលិក

១. បង្កើតគោលនយោបាយអភិវឌ្ឍន៍បុគ្គលិក។

២. ពង្រឹងសមត្ថភាពបុគ្គលិក។

## III- ការអភិវឌ្ឍវគ្គបណ្តុះបណ្តាល

១. បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមសម្រាប់បម្រើការនៅតាមវិទ្យាល័យទាំងគ្រឹះស្ថានសាធារណៈ និងឯកជន។
២. វិក្រិតការគ្រូបង្រៀនកម្រិតឧត្តម។
៣. បណ្តុះបណ្តាលជំនាញផែនការ និងការងារគ្រប់គ្រង។
៤. បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។

## IV- ការវាយតម្លៃ

១. បង្កើតលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃគរុនិស្សិត និងគ្រូឧទ្ទេស។
២. បង្កើតស្តង់ដារក្នុងការវាយតម្លៃ។
៣. កសាងសមត្ថភាពគ្រូឧទ្ទេស និងគរុនិស្សិតស្តីអំពីស្តង់ដារ និងលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ។
៤. រៀបចំប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់រង្វាន់ដល់គ្រូឧទ្ទេស និងគរុនិស្សិត។

## V- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១. បង្កើតប្លង់មេរបស់វិទ្យាស្ថានជាតិអប់រំ។
២. សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបំពាក់សម្ភារបរិក្ខារ។
៣. ថែទាំជួសជុលហេដ្ឋារចនាសម្ព័ន្ធ។

## VI- ការធានាគុណភាព

១. កសាងស្តង់ដារធានាគុណភាពអប់រំផ្ទៃក្នុង។
២. អភិវឌ្ឍសមត្ថភាពបុគ្គលិកអំពីជំនាញវាយតម្លៃគុណភាពអប់រំ។
៣. រៀបចំឲ្យមានការវាយតម្លៃពីខាងក្រៅ។

## VII- ការស្រាវជ្រាវ

១. កសាងស្តង់ដារសម្រាប់បុគ្គលិក និងគរុនិស្សិត។
២. លើកកម្ពស់សមត្ថភាពបុគ្គលិក និងគរុនិស្សិតឲ្យធ្វើការស្រាវជ្រាវតាមមន្ទីរពិសោធន៍ សហគមន៍ និងទស្សនាវដ្តីជាតិ និងអន្តរជាតិ។
៣. បោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានស្តីពីលទ្ធផលស្រាវជ្រាវឲ្យបានទៀងទាត់និងទូលំទូលាយ។

## VIII- ការកសាងទំនាក់ទំនង

១. បង្កើតកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យរដ្ឋ ឯកជនជាតិ និងអន្តរជាតិ។
២. បង្កើតទំនាក់ទំនងការងារល្អជាមួយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យ និងវិក្រិត-ការខេត្ត-រាជធានី។
៣. បង្កើតទំនាក់ទំនងការងារល្អជាមួយវិទ្យាល័យ។
៤. បង្កើតទំនាក់ទំនងល្អជាមួយដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ។

# សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចផែនការនេះវិទ្យាស្ថានជាតិអប់រំ នឹងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ។ ក្នុងការអនុវត្តផែនការនេះ គណៈគ្រប់គ្រងវិទ្យាស្ថានជាតិអប់រំ នឹងធានាថាអ្នកពាក់ព័ន្ធ នឹងមានឱកាសចូលរួមក្នុងការសម្រេចចិត្ត ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការបញ្ចូលយេនឌ័រ ជនពិការ និងជនជាតិភាគតិចនៅក្នុងផែនការនេះ។

ដើម្បីធានាការអនុវត្តផែនការយុទ្ធសាស្ត្រជាគន្លឹះនេះ វិទ្យាស្ថានជាតិបានបង្កើតទស្សនៈវិស័យដ៏ទូលំទូលាយមួយដែលរាប់បញ្ចូលយ៉ាងលម្អិតនូវលទ្ធផលរំពឹងទុក សូចនាករ និងរយៈពេលសម្រាប់ធ្វើសកម្មភាពនីមួយៗ ។